គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍សង្ខេប

## ពិធីបើកកិច្ចប្រជុំពិគ្រោះយោបល់លើកទី២ កម្រិតថ្នាក់ដឹកនាំបច្ចេកទេស នៃប្រទេសបញ្ជូនទាំងបី (កម្ពុជា ឡាវ មីយ៉ាន់ម៉ា) ស្តីពី តួនាទីប្រទេសបញ្ជូន ដើម្បីពង្រឹងកិច្ចការពារពលករទេសន្តរប្រវេសន៍

ថ្ងៃពុធ-ព្រហស្បតិ៍ ៣-៤កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី៣០-៣១ ខែតុលា ឆ្នាំ២០១៩ វេលាម៉ោង ៩ និង០០ នាទីព្រឹក នៅសណ្ឋាគារសុខាល័យអង្គរ ទីរួមខេត្តសៀមរាប មានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់លើកទី២ កម្រិតថ្នាក់ដឹកនាំបច្ចេកទេស នៃប្រទេសបញ្ជូនទាំងបី (កម្ពុជា ឡាវ មីយ៉ាន់ម៉ា) ស្តីពី "**តួនាទីប្រទេសបញ្ជូន ដើម្បីពង្រឹងកិច្ចការពារពលករទេសន្តរប្រវេសន៍**" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ដោយមានការអញ្ជើញចូលរួមពី **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ (តំណាងភាគីកម្ពុជា), និងឯកឧត្តម លោកជំទាវ តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, តំណាងក្រសួងកិច្ចការនារី, តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, តំណាងក្រសួងអប់រំ យុវជន និងកីឡា,តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ, អភិបាល នៃគណៈអភិបាលខេត្តព្រះវិហារ, អភិបាល នៃគណៈអភិបាលខេត្តប៉ៃលិន, អភិបាលរងខេត្តសៀមរាប, អភិបាលរងខេត្តជាប់ព្រំដែនកម្ពុជា-ថៃ, លោកជំទាវ នាយឧត្តមសេនីយ៍ អគ្គស្នងការរងនគរបាលជាតិ, លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជបណ្ឌិត អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ, តំណាងអគ្គនាយកដ្ឋានអន្តោប្រវេសន៍, ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង គ.ជ.ប.ជ, ឯកឧត្តម ឧត្តមសេនីយ៍ឯក ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គ ស្នងការដ្ឋាននគរបាលជាតិ, ស្នងការ ស្នងការរង នៃស្នងការដ្ឋាននគរបាលខេត្ត, មន្ត្រីរាជការ នៃមន្ទីរជុំវិញខេត្តសៀមរាប អង្គការដៃគូពាក់ព័ន្ធ ភ្ញៀវជាតិ អន្តរជាតិ និងមន្ត្រីជំនាញ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មួយចំនួនទៀត សរុបចំនួន ៨២ រូប ស្រី ១៩ រូប។

តំណាងភាគីឡាវ ដឹកនាំដោយលោក វរៈសេនីយ៍ឯក បណ្ឌិត **ផេងសាវ៉ាញ់ ធីផាវង្សសៃ** (Pol.Col.Dr. Phengsavanh Thipphavongsay) អគ្គស្នងការរង នៃអគ្គស្នងការដ្ឋាននគរបាល និងជាប្រធានលេខាធិការដ្ឋាន គណៈកម្មាធិការជាតិប្រឆាំងការជួញដូរមនុស្ស ក្រសួងសន្តិសុខសាធារណៈ នៃសាធារណរដ្ឋប្រជាមានិតឡាវ និងសមាជិកប្រតិភូ ចំនួន ៤ រូប ។

តំណាងភាគីមីយ៉ាន់ម៉ា ដឹកនាំដោយ **ឯកឧត្តម ឧត្តមសេនីយ៍ឯក អោង ធូ** (Aung Thu) អនុរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៃសហភាពមីយ៉ាន់ម៉ា និងសមាជិកប្រតិភូ ចំនួន ៤ រូប ។

ជាកិច្ចចាប់ផ្ដើម **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញឡើងមានមតិស្វាគមន៍ចំពោះវត្តមានដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចក្រឡាហោម** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ គណៈប្រតិភូទាំងពីរប្រទេស ព្រមទាំង ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ ទាំងអស់ដែលមានវត្តមានក្នុងអង្គប្រជុំនេះផងដែរ។

លោកជំទាវ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានមានប្រសាសន៍ពាក់ព័ន្ធនឹងកិច្ចប្រជុំថា៖ នេះជាលើកទី២ហើយ ដែលគណៈប្រតិភូ នៃប្រទេសយើងទាំងបីបានជួបជុំគ្នា ដើម្បីពិភាក្សារកដំណោះស្រាយបញ្ហាប្រឈមរបស់ប្រជាពលរដ្ឋយើង ដែលបាននិងកំពុង ធ្វើទេសន្តរប្រវេសន៍ការងារនៅក្រៅប្រទេស ជាពិសេសក្នុងប្រទេសថៃ ។ កាលពីថ្ងៃទី ២៤ និង២៥ ខែឧសភា ឆ្នាំ២០១៨ កន្លងទៅ យើងបានជួបជុំគ្នានៅទីនេះដែរជាកិច្ចប្រជុំលើកទី១ តែជាការចាប់ផ្ដើម មិនទាន់មានលទ្ធផលជាផ្លែផ្កានៅឡើយ។ ដូច្នេះ ក្នុងកិច្ចប្រជុំលើកទី២ ថ្នាក់មន្ត្រីជាន់ខ្ពស់កម្រិតបច្ចេកទេសនេះ យើងនឹងពិភាក្សាដោយបើកចំហជាលក្ខណៈមិត្តភាព ដើម្បីរកឲ្យឃើញនូវបញ្ហាដែលជាអាទិភាព បទពិសោធន៍ក្នុងការដោះស្រាយ និងគំនិតផ្ដួចផ្ដើមក្នុងការធ្វើឲ្យប្រសើរឡើងនូវកិច្ចការពារសុវត្ថិភាព ព្រមទាំងសិទ្ធិ និងផលប្រយោជន៍របស់ពលករ របស់ប្រទេសយើងផងដែរ ។

គោលបំណងសំខាន់ នៃកិច្ចប្រជុំគឺ៖

ទី១. ស្វែងយល់អំពីស្ថានភាព និងទំនោរនៃទេសន្តរប្រវេសន៍បច្ចុប្បន្ន ដើម្បីរិះរកវិធានការ ក្នុងការលុបបំបាត់ការធ្វើទេសន្តរប្រវេសន៍មិនប្រក្រតី ការជួញដូរមនុស្ស និងរាល់ទម្រង់នៃអំពើកេងប្រវ័ញ្ចក្នុងវដ្ដ នៃទេសន្តរប្រវេសន៍ និងលើកកម្ពស់ ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព របៀបរយ និងស្របច្បាប់ ។

ទី២. កំណត់រកបញ្ហារួម និងផ្លាស់ប្ដូរ មេរៀនបទពិសោធន៍ល្អៗ ក្នុងការដោះស្រាយបញ្ហាទាំងនោះ តាមរយៈការពង្រឹងកិច្ចសហការក្នុងការឆ្លើយតបទៅនឹងការងារបង្ការទប់ស្កាត់ ការអនុវត្តច្បាប់ និងកិច្ចការពារជនរងគ្រោះ នៅក្នុងប្រទេសរៀងៗខ្លួន ក៏ដូចជាក្នុងប្រទេសគោលដៅ ។

មតិចូលរួម និងចំណាប់អារម្មណ៍ក្នុងកិច្ចប្រជុំដោយ **លោកស្រី គ្រីស្ទីន ផាកូ** (Ms.KRISTIN Parco) ប្រធានបេសកកម្មអង្គការអន្តរជាតិទេសន្តរប្រវេសន៍ប្រចាំកម្ពុជា (IOM) គាំទ្រចំពោះការជួបប្រជុំគ្នារវាងប្រទេសជាសមាជិក (កម្ពុជា ឡាវ មីយ៉ាន់ម៉ា)។ **លោកស្រី គ្រីស្ទីន** បានបញ្ជាក់ថា យើងត្រូវធ្វើការរួមគ្នាដើម្បីធ្វើឲ្យពលករទេសន្តរប្រវេសន៍មានជម្រើសច្បាស់លាស់ និងមិនធ្វើចំណាកស្រុកដោយសារការចាំបាច់ ។ ដើម្បីសិទ្ធិ និងសេចក្ដីថ្លៃថ្នូររបស់ពួកគាត់យើងត្រូវប្រឹងប្រែងបន្ថែមទៀត ក្នុងការរក្សាភាពជាដៃគូ ការចែករំលែក និងការទទួលខុសត្រូវយ៉ាងពិតប្រាកដ ដើម្បីទទួលបានផលប្រយោជន៍ និងគោលដៅរួមទាំងអស់គ្នា ហើយសង្ឃឹមថាកិច្ចប្រជុំនេះនឹងទទួលបានលទ្ធផលល្អក្នុងកិច្ចការពារពលករទេសន្តរប្រវេសន៍ ដែលកំពុងធ្វើការនៅប្រទេសគោលដៅ ។

មតិចូលរួម និងចំណាប់អារម្មណ៍របស់ លោកវរៈសេនីយ៍ឯក បណ្ឌិត **ផេងសាវ៉ាញ់ ធីផាវុង្សៃ** (Pol.Col.Dr. Phengsavanh Thipphavongsay)អគ្គស្នងការរង នៃអគ្គស្នងការដ្ឋាននគរបាល និងជាប្រធានលេខាធិការដ្ឋាន គណៈកម្មាធិការជាតិប្រឆាំងការជួញដូរមនុស្ស ក្រសួងសន្តិសុខសាធារណៈ នៃសាធារណរដ្ឋប្រជាមានិតឡាវ និងមតិចូលរួម និងចំណាប់អារម្មណ៍របស់ **ឯកឧត្តម ឧត្តមសេនីយ៍ឯក អោង ធូ** (Aung Thu) អនុរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ នៃសហភាពមីយ៉ាន់ម៉ា បង្ហាញឆន្ទៈក្នុងការចូលរួមក្នុងការចូលរួមកិច្ចប្រជុំពិគ្រោះយោបល់លើកទី២ នេះដើម្បីរកដំណោះស្រាយរួមគ្នា។

សុន្ទរកថាបើក និងប្រសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ ។ សម្តេចមានប្រសាសន៍ថ្លែងអំណរគុណ ចំពោះការអញ្ជើញចូលរួមរបស់គណៈប្រតិភូទាំងបីប្រទេស កម្ពុជា ឡាវ និងភូមា និងភ្ញៀវជាតិអន្តរជាតិទាំងអស់ ក្នុងកិច្ចប្រជុំពិគ្រោះយោបល់កម្រិតបច្ចេកទេសថ្នាក់មន្ត្រីជាន់ខ្ពស់ ស្តីពី "តួនាទីប្រទេសបញ្ជូនក្នុងកិច្ចការពារពលករទេសន្តរប្រវេសន៍" ដែលកំពុងតែប្រារព្ធធ្វើឡើង នាទីក្រុងសៀមរាបអង្គរ ខេត្តសៀមរាប នៃព្រះរាជាណាចក្រកម្ពុជា ។

**សម្តេចក្រឡាហោម** ប្រធានអង្គប្រជុំ បានមានប្រសាសន៍បន្តថាៈ យើងទទួលស្គាល់ការធ្វើទេសន្តរប្រវេសន៍ គឺជាសិទ្ធិពលរដ្ឋ ក្នុងការជ្រើសរើសការងារ មុខរបរ និងទីកន្លែងរស់នៅ តែយើងក៏ត្រូវគិតអំពីសិទ្ធិផលប្រយោជន៍ និងសេចក្តីថ្លៃថ្នូរក្នុងនាមជាមនុស្សរបស់ពលករ ការគ្រប់គ្រង និងកិច្ចការពារពលរដ្ឋរបស់យើងក្នុងនាមជាប្រទេសដែលមានអធិបតេយ្យភាព និងទំនាក់ទំនងល្អរវាងប្រទេសជិតខាង និងរវាងប្រទេសបញ្ជូន និងប្រទេសទទួលផងដែរ ។ ទាំងនេះ គឺជាតួនាទីរបស់ប្រទេសយើងទាំងបី ដែលជាប្រទេសបញ្ជូន ដែលចាំបាច់ត្រូវរួមសហការគ្នាក្នុងការដោះស្រាយបញ្ហារួម ។

កិច្ចពិភាក្សាពិគ្រោះយោបល់កម្រិតបច្ចេកទេស ថ្នាក់មន្ត្រីជាន់ខ្ពស់ ស្តីពី "**តួនាទីប្រទេសបញ្ជូនក្នុងកិច្ចការពារពលករទេសន្តរប្រវេសន៍**" នេះ គឺជាការផ្តួចផ្តើមដ៏មានសារសំខាន់ ហើយក៏ជាការបំពេញករណីយកិច្ច របស់យើងដែលជាប្រទេសសមាជិកក្នុងតំបន់ និងក្នុងពិភពលោក ក្នុងការពង្រឹងកិច្ចសហការស្វែងរកគន្លឹះដោះស្រាយរួមគ្នា រវាងប្រទេសដែលមានស្ថានភាពប្រហាក់ប្រហែលគ្នា ហើយក៏ជាការបង្ហាញអំពីឆន្ទៈនយោបាយ និងការប្តេជ្ញាចិត្ត ក្នុងកិច្ចការពារសិទ្ធិ និងផលប្រយោជន៍ពលករពីភាពរងគ្រោះ និងជនរងគ្រោះគ្រប់ភេទ គ្រប់វ័យ ក្នុងអំឡុងពេលទេសន្តរប្រវេសន៍ ជាពិសេសពីអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចគ្រប់រូបភាព ដែលនឹងផ្តល់ផលប្រយោជន៍ប្រកបដោយសមធម៌សម្រាប់ភាគីទាំងសងខាង គឺនិយោជក និងនិយោជិត និងរវាងប្រទេសបញ្ជូន និងប្រទេសទទួល ។

ជាថ្មីម្តងទៀត ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាមគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សង្ឃឹមថាៈ កិច្ចពិភាក្សានេះ នឹងទទួលបានលទ្ធផលជាផ្លែផ្កា ដែលប្រតិភូនីមួយៗនឹងអាចនាំយកលទ្ធផលនៃកិច្ចពិភាក្សា ទៅដាក់ជូនថ្នាក់ដឹកនាំរដ្ឋាភិបាល ដើម្បីធ្វើការសម្រេចចិត្ត ក្នុងការធ្វើឲ្យក្លាយជាសកម្មភាពជាក់ស្តែងក្នុងការគ្រប់គ្រងទេសន្តរប្រវេសន៍ និងកិច្ចការពារប្រជាពលរដ្ឋពីភាពរងគ្រោះដោយអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចគ្រប់រូបភាព និងឈានទៅការជួបគ្នារវាងថ្នាក់ដឹកនាំប្រទេសទាំងបី ដើម្បីសម្រេចលើសេចក្តីថ្លែងការណ៍រួមដំណោះស្រាយរួម នៅពេលអនាគតដ៏ខ្លីខាងមុខ និងអាចដាក់ស្នើការពិភាក្សា ជាមួយភាគីថៃ ដើម្បីរួមសហការគ្នាដោះស្រាយបញ្ហាពលករឲ្យបានរលូន និងមានប្រសិទ្ធភាព ។

**សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ បានផ្តល់អនុសាសន៍ខ្ពង់ខ្ពស់បន្ថែមទៀត នៅក្នុងពិធីបើកកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់មន្ត្រីជាន់ខ្ពស់កម្រិតបច្ចេកទេស ស្តីពី តួនាទីប្រទេសបញ្ជូនក្នុង«កិច្ចការពារពលករទេសន្តរប្រវេសន៍» ថាៈ

- សូមឲ្យប្រទេសនីមួយៗបង្កើតការងារក្នុងស្រុកឲ្យបានច្រើនសម្រាប់ប្រជាពលរដ្ឋមានការងារធ្វើ ជៀសវៀងការធ្វើចំណាកស្រុកដោយប្រថុយប្រថាន។
- ពលករដែលធ្វើចំណាកស្រុករបស់ប្រទេសនីមួយៗ ក៏ដូចជាពលកររបស់ខ្លួនដែរ ដូច្នេះយើងត្រូវធ្វើការ

ការពារចំពោះគាត់គ្រប់ពេលវេលានៅពេលគាត់កំពុងធ្វើការងារ ឬរស់នៅប្រទេសគោលដៅ។

- ការជួបប្រជុំគ្នាលើកនេះ គឺមិនមែនជាការជួបប្រជុំដើម្បីធ្វើការគាបសង្កត់ប្រទេសថៃទេ ។ ដូចនេះយើងត្រូវរួមគ្នាស្វែងរកនូវបញ្ហាប្រឈមនានា និងរិះរកវិធីសាស្ត្រដំណោះស្រាយ ដើម្បីធ្វើការជួបពិភាក្សាជាមួយភាគីប្រទេសគោលដៅ ក្នុងការជួយដល់ពលករទេសន្តរប្រវេសន៍ ក៏ដូចជាជួយដល់រដ្ឋាភិបាល នៃប្រទេសនីមួយៗផងដែរ។
- ចំពោះលទ្ធផល នៃកិច្ចប្រជុំកម្រិតជំនាញបច្ចេកទេសលើកនេះត្រូវបញ្ជូនទៅថ្នាក់ដឹកនាំ នៃប្រទេសនីមួយៗ ដើម្បីធ្វើការសម្រេច ។ បន្ទាប់មកយើងនឹងធ្វើការជួបប្រជុំពិភាក្សាជាមួយមន្ត្រីជាន់ខ្ពស់ជំនាញបច្ចេកទេសប្រទេសថៃ ហើយយើងនឹងរៀបចំកិច្ចប្រជុំលើការងារនេះរវាងប្រទេសទាំង ៤(កម្ពុជា ថៃ ឡាវ មីយ៉ាន់ម៉ា)។
- កិច្ចប្រជុំនេះ គឺយើងផ្តោតសំខាន់លើកិច្ចការពារទេសន្តរប្រវេសន៍ គឺសំដៅលើអ្នកដែលចាកចេញហើយសូមកុំយករឿងផ្សេងៗមកពាក់ព័ន្ធនាំឲ្យមានភាពស្មុគស្មាញ និងអូសបន្លាយពេលវេលា។

**សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ មានប្រសាសន៍ជូនពរ ចំពោះគណៈប្រតិភូទាំងពីរប្រទេស និងឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំ ភ្ញៀវជាតិ អន្តរជាតិ តំណាងអង្គការដៃគូ និងមន្ត្រីរាជការទាំងអស់ដែលមានវត្តមានពេលនេះ។ បន្ទាប់មក **សម្តេចក្រឡាហោម** ធ្វើការប្រកាសបើកកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់មន្ត្រីជាន់ខ្ពស់ កម្រិតបច្ចេកទេស ស្តីពី តួនាទីប្រទេសបញ្ជូនក្នុង «កិច្ចការពារពលករទេសន្តរប្រវេសន៍»។

ចុងបញ្ចប់ នៃពិធីបើកកិច្ចប្រជុំពិគ្រោះយោបល់ ស្តីពី តួនាទីប្រទេសបញ្ជូនក្នុង«កិច្ចការពារពលករទេសន្តរប្រវេសន៍» សម្តេចក្រឡាហោម បានផ្តល់កិត្តិយសដ៏ខ្ពង់ខ្ពស់អញ្ជើញថតរូបអនុស្សាវរីយ៍ជាមួយគណៈប្រតិភូ និងថ្នាក់ដឹកនាំទាំងបីប្រទេស ព្រមទាំងភ្ញៀវជាតិ អន្តរជាតិ ដែលបានអញ្ជើញចូលរួម។

13/11/19

ថ្ងៃ ១៥ ១០ កើត ខែ កត្តិក ឆ្នាំកុរ ឯស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ២០១៩
**អ្នកធ្វើរបាយការណ៍**

វរសេនីយ៍ទោ ឡឹក_សត្យា

**គោរពជូន**
**លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**
មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។
ថ្ងៃ ... ១៦ កើត ខែ កត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០១៩
**អគ្គលេខាធិការរង**

ឧត្តមសេនីយ៍ឯក. យឹម_ទិរៈ

**សមាសភាពចូលរួមជាគណៈអធិបតី**

**ពិធីបើក នៃកិច្ចប្រជុំពិគ្រោះយោបល់លើកទី២ កម្រិតថ្នាក់ដឹកនាំបច្ចេកទេស**

**នៃប្រទេសបញ្ជូនទាំងបី (កម្ពុជា ឡាវ មីយ៉ាន់ម៉ា) ស្តីពី តួនាទីប្រទេសបញ្ជូន**

**ដើម្បីពង្រឹងកិច្ចការពារពលករទេសន្តរប្រវេសន៍**

ថ្ងៃពុធ-ព្រហស្បតិ៍ ៣-៤កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ត្រូវនឹងថ្ងៃទី៣០-៣១ ខែតុលា ឆ្នាំ២០១៩ នៅសណ្ឋាគារសុខាល័យអង្គរ ខេត្តសៀមរាប

១.វ.ឯក បណ្ឌិត **ផេងសាវ៉ាញ់ ធីផាវងសៃ** (Pol.Col.Dr. Phengsavanh Thipphavongsay) អគ្គស្នងការរង នៃអគ្គស្នងការដ្ឋាននគរបាល និងជាប្រធានលេខាធិការដ្ឋាន គណៈកម្មាធិការជាតិប្រឆាំងការជួញដូរមនុស្ស ក្រសួងសន្តិសុខសាធារណៈ នៃសាធារណរដ្ឋ ប្រជាមានិតឡាវ និងមន្ត្រីបច្ចេកទេស ចំនួន ៥ រូប

២.ឯ.ឧ.ឯ **អោង ធូ** (Aung Thu) អនុរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៃសហភាពមីយ៉ាន់ម៉ា និងមន្ត្រីបច្ចេកទេស ចំនួន ៥ រូប

៣.**លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និង ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៃព្រះរាជាណាចក្រកម្ពុជា ចំនួន ១៧ រូប ។

| | | |
|---|---|---|
| ៤.ឯកឧត្តម | ញឹក វណ្ណារ៉ា | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| ៥.លោកជំទាវ | ហ៊ូ សាមិត្ត | រដ្ឋលេខាធិការក្រសួងកិច្ចការនារី |
| ៦.ឯកឧត្តម | ហ៊ូ វុឌ្ឍី | អនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ៧.លោកជំទាវ | សឿ សុជាតា | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា |
| ៨.ឯកឧត្តម | កែ ពិសិដ្ឋ | អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ |
| ៩.ឯកឧត្តម | រឿន រិទ្ធីរ័ត្ន | អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| ១០.ល.នាយ | យក់ សុខា | អគ្គស្នងការរងនគរបាលជាតិ |
| ១១.ល.ឧ.ឯក | ប៉ុណ្ណ សំខាន់ | អគ្គលេខាធិការ គ.ជ.ប.ជ |
| ១២.ឯកឧត្តម | ប្រាក់ សុវណ្ណ | អភិបាល នៃគណៈអភិបាលខេត្តព្រះវិហារ |
| ១៣.ឯកឧត្តម | ផាន់ ចាន់ធុល | អភិបាល នៃគណៈអភិបាលខេត្តប៉ៃលិន |
| ១៤.ល.ជំ | យូ សុភា | អភិបាលរង ខេត្តសៀមរាប |
| ១៥.ឯ.ឧ.ឯក | អ៊ិក ហៃសីឡា | អគ្គនាយករង នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ |
| ១៦.ឯ. ឧ.ឯក | ខៀវ ចាន់រ៉ា | អគ្គលេខាធិការរង គ.ជ.ប.ជ |
| ១៧.ឯ.ឧ.ឯក | យឹម វិរៈ | អគ្គលេខាធិការរង គ.ជ.ប.ជ |
| ១៨.ឯ.ឧ.ឯក | យ៉ែម ច័ន្ទណារុំ | អគ្គលេខាធិការរង គ.ជ.ប.ជ |
| ១៩.ល.ឧ.ទោ | រ៉ន សិរីលក្ខិណា | អគ្គលេខាធិការរង គ.ជ.ប.ជ |
| ២០.ឯ.ឧ.ឯក | ជីវ ផល្លី | ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន |

២១.តំណាងអង្គការដៃគូពាក់ព័ន្ធ

២២.ភ្ញៀវជាតិ អន្តរជាតិ

២៣.មន្ត្រីពាក់ព័ន្ធ នៃអគ្គលេខធិការដ្ឋន គ.ជ.ប.ជ និងមន្ទីរជុំវិញខេត្តសៀមរាប

**សរុបចំនួនៈ ៨២ រូប/ ស្រី ១៩ រូប**